01047332

E315/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 12 / 2014
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**សាធារណៈ / Public**

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤

**ជូនចំពោះ:** **ភាគីទាំងអស់នៃសំណុំរឿង ០០២/០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ព័ត៌មានអំពី (១) សវនាការលើការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២**

១. អង្គជំនុំជម្រះសាលាដំបូងសូមយកឱកាសនេះ ដើម្បីផ្តល់ព័ត៌មានជូនភាគីទាំងអស់អំពីការធ្វើសវនាការលើការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២។

*(១) សវនាការលើការបង្ហាញឯកសារគន្លឹះ*

២. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានបង្កើតជាទម្លាប់នៃការអនុវត្តក្នុងការធ្វើសវនាការលើការបង្ហាញឯកសារគន្លឹះទាំងឡាយ ដែលផ្តល់ឱកាសឱ្យភាគីដាក់បង្ហាញឯកសារគន្លឹះនានាដែលខ្លួនយល់ថា មានការពាក់ព័ន្ធជាពិសេសទៅនឹងអង្គហេតុនីមួយៗសម្រាប់ការជំនុំជម្រះ (*សូមមើលឯកសារ* E170 និង E288/1/1)។ សវនាការលើការបង្ហាញឯកសារគន្លឹះទាំងនេះ ធ្វើឡើងដោយពិចារណាថា ឯកសារភ័ស្តុតាងទាំងអស់ មិនមែនតែងតែត្រូវបានលើកយកមកបង្ហាញនៅក្នុងអំឡុងពេលនៃការសួរ

ដេញដោលបុគ្គលដែលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនោះទេ ហើយសវនាការនេះក៏បានផ្តល់ឱកាសដល់សាធារណជន ក្នុងការមើលឯកសារដែលជាផ្នែកមួយនៃការជំនុំជម្រះផងដែរ។

៣. អង្គជំនុំជម្រះជូនដំណឹងដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះនឹងបន្តការអនុវត្តនេះនៅក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះនឹងធ្វើសវនាការលើការបង្ហាញឯកសារគន្លឹះ នៅពេលសវនាការលើអង្គហេតុនីមួយៗត្រូវបានបញ្ចប់ (*សូមមើលឯកសារ* E315)។ សវនាការលើការបង្ហាញឯកសារគន្លឹះនីមួយៗ នឹងកម្រិតត្រឹមតែការពិភាក្សាលើឯកសារដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានជំនុំជម្រះនីមួយៗតែប៉ុណ្ណោះ។

៤. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សវនាការលើការបង្ហាញឯកសារគន្លឹះ គឺខុសគ្នាពីនីតិវិធីនៃការទទួលយកឯកសារ។ នៅក្នុងអំឡុងពេលសវនាការលើការបង្ហាញឯកសារគន្លឹះ ភាគីអាចយោងទៅលើឯកសារដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ (គឺឯកសារដែលមានលេខសំគាល់ E3 រួចហើយ) ព្រមទាំងឯកសារទាំងឡាយដែលភាគីបានកំណត់ពីមុនថាមានភាពពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ផងដែរ។ អង្គជំនុំជម្រះនឹងធ្វើតាមការអនុវត្តពីមុនរបស់ខ្លួន ដោយអនុញ្ញាតឱ្យភាគីនានា និងជនជាប់ចោទផ្តល់យោបល់ទៅលើឯកសារដែលភាគីម្ខាងទៀតបានដាក់បង្ហាញ ប្រសិនបើពួកគេមានចេតនាធ្វើដូច្នេះ (*សូមមើល* ប្រតិចារឹក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៦៩-៧០, ៨៩-៩០)។

៥. អង្គជំនុំជម្រះ បង្គាប់ឱ្យភាគីទាំងអស់ជ្រើសរើសឯកសារគន្លឹះក្នុងចំនួនមានកម្រិត ដែលពាក់ព័ន្ធទៅនឹងអង្គហេតុនីមួយៗសម្រាប់ការបង្ហាញនៅក្នុងសវនាការ ហើយបញ្ជូនបញ្ជីឯកសារទាំងនោះមកអង្គជំនុំជម្រះ និងភាគីទាំងអស់ មុនពេលសវនាការលើការបង្ហាញឯកសារគន្លឹះនីមួយៗ។ អង្គជំនុំជម្រះស្នើឱ្យភាគីទាំងអស់ជៀសវៀងការបង្ហាញឯកសារច្រំដែល ដោយមិនត្រូវជ្រើសរើសឯកសារទាំងឡាយណាដែលត្រូវបានពិភាក្សាពិស្តារក្នុងកិច្ចដំណើរការនីតិវិធីសវនាការពីមុនរួចហើយនោះទេ។

៦. អង្គជំនុំជម្រះនឹងប្រកាសពីកាលបរិច្ឆេទ និងការបែងចែកពេលវេលាសម្រាប់សវនាការលើការបង្ហាញឯកសារគន្លឹះនីមួយៗ នៅពេលសមស្របខាងមុខ។

*(២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណី*

៧. អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងដល់ភាគីទាំងអស់ថា នៅចុងបញ្ចប់នៃសវនាការលើអង្គហេតុនីមួយៗ (*សូមមើល*ឯកសារ E315) បន្ទាប់ពីការធ្វើសវនាការលើការបង្ហាញឯកសារគន្លឹះ

អង្គជំនុំជម្រះនឹងកំណត់រយៈពេលចំនួនពីរថ្ងៃ សម្រាប់ធ្វើសវនាការស្តាប់តំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលបានជ្រើសរើស និងមានភាពពាក់ព័ន្ធជាចម្បងទៅនឹងអង្គហេតុដែលត្រូវបានជំនុំជម្រះជាពិសេស អំពីផលប៉ះពាល់ដែលពួកគេបានទទួលរងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (*សូមមើល* ឯកសារ E218 កថាខណ្ឌ ១៨ផងដែរ)។

៨. អង្គជំនុំជម្រះសូមរំលឹកដល់ភាគីអំពីការអនុវត្តពីមុនរបស់ខ្លួន ពាក់ព័ន្ធនឹងភាពខុសគ្នារវាងសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីលើអង្គហេតុសម្រាប់ជំនុំជម្រះ និងសេចក្តីថ្លែងទូទៅអំពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី (*សូមមើល* ឯកសារ E267/3 កថាខណ្ឌ ១៤)។ អនុលោមតាមការអនុវត្តនេះ អង្គជំនុំជម្រះនឹងតម្រូវឱ្យការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី កម្រិតត្រឹមតែអង្គហេតុទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ប៉ុណ្ណោះ រីឯការធ្វើសេចក្តីថ្លែងទូទៅពីការឈឺចាប់ មិនតម្រូវឱ្យធ្វើការបែងចែកដាច់ពីគ្នារវាងព្យសនកម្មដែលកើតឡើងដោយសារអង្គហេតុដែលស្ថិតក្នុងវិសាលភាពសំណុំរឿង និងព្យសនកម្មទូទៅដែលបង្កឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ហើយការថ្លែងអំពីការឈឺចាប់នេះ គឺមិនត្រូវបំពានទៅលើសិទ្ធិរបស់ជនជាប់-ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឡើយ។ ក្នុងករណីដែលសេចក្តីថ្លែងពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហើបនូវអង្គហេតុថ្មី ឬ ការចោទប្រកាន់ថ្មីប្រឆាំងនឹងជនជាប់ចោទដែលមិនទាន់បានពិភាក្សាដេញដោលនោះ អង្គជំនុំជម្រះអាចពិចារណាដើម្បីផលប្រយោជន៍យុត្តិធម៌ក្នុងការផ្តល់ឱកាសឱ្យភាគី តាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនោះ ពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងនោះបាន។

៩. អង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលសមស្របខាងមុខ។ អង្គជំនុំជម្រះសូមជូនដំណឹងដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា តាមការអនុវត្តកន្លងមកនៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំ-ជម្រះនឹងស្នើឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ផ្តល់នូវបញ្ជីអាទិភាពនៃដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគេមានបំណងក្នុងការស្តាប់សក្ខីកម្មនៅក្នុងអង្គហេតុសម្រាប់ជំនុំជម្រះនីមួយៗឱ្យបានមុនពេលសវនាការលើព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី (*សូមមើល* ឯកសារ E236/5 កថាខណ្ឌ ៤)។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺជាអ្នកកំណត់ពីការប្រើប្រាស់ពេលវេលាដែលអង្គជំនុំជម្រះបានបែងចែកឱ្យ ហើយអង្គជំនុំជម្រះនឹងមិនសម្រេចផ្តល់ពេលវេលាបន្ថែមឡើយ។